# **សារលិខិតរំលែកទុក្ខ**

ក្រសួងមុខងារសាធារណៈ
ចូលរួមរំលែកទុក្ខយ៉ាងក្រៀមក្រំបំផុត
ជូនចំពោះ

**លោកស្រី ទ្រាក់ ពៅ និងក្រុមគ្រួសារសព ឧត្តមសេនីយ៍ទោ ស សាវី**



ក្នុងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងមុខងារសាធារណៈសូមចូលរួមរំលែកមរណទុក្ខ យ៉ាងក្រៀមក្រំបំផុតជាមួយក្រុមគ្រួសារសព **ឧត្តមសេនីយ៍ទោ ស សាវី** ដែលបានទទួលមរណភាព ដោយជំងឺកូវីដ១៩ ក្នុងបុព្វហេតុបំពេញបេសកកម្មមនុស្សធម៌អង្គការសហប្រជាជាតិ កាលពីថ្ងៃ២៩ ខែឧសភា ឆ្នាំ២០២០ នៅប្រទេសម៉ាលី។

មរណភាពរបស់ **ឧត្តមសេនីយ៍ទោ ស សាវី** គឺជាការបាត់បង់ស្វាមី ឪពុក និងជីតា ប្រកបដោយព្រហ្មវិហារធម៌ និងជាការបាត់បង់យុទ្ធជនដ៏ឆ្នើមមួយរូបរបស់កម្ពុជា ដែលពោរពេញដោយឆន្ទៈ មនសិការក្នុងការបំពេញបេសកកម្មជូនជាតិ និងអង្គការសហប្រជាជាតិ។

ក្រសួងមុខងារសាធារណៈ សូមគោរពដោយស្មោះស្ម័គ្រចំពោះវីរភាព និងពលីកម្មរបស់ **ឧត្តមសេនីយ៍ទោ ស សាវី** ក្នុងបុព្វហេតុជូនជាតិ និងអង្គការសហប្រជាជាតិ។

សូមវិញ្ញាណក្ខន្ធរបស់
**ឧត្តមសេនីយ៍ទោ ស សាវី**
បានដល់សុគតិភព កុំបីឃ្លៀងឃ្លាតឡើយ៕